# កម្រងសំណួរដែលត្រូវបានសួរជាញឹកញាប់ សម្រាប់ "គម្រោងអនាគតរបស់គ្រួសារខ្ញុំ ជាមួយមេនូឡាយហ្វ៍"

## 1. តើអ្វីទៅជាគម្រោងអនាគតរបស់គ្រួសារខ្ញុំ ជាមួយមេនូឡាយហ្វ៍?

- គម្រោងអនាគតរបស់គ្រួសារខ្ញុំ ជាមួយមេនូឡាយហ្វ៍ ត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់ការការពារដល់អ្នកត្រូវបានធានាអាយុជីវិត ប្រសិនបើគាត់ជួបគ្រោះអកុសលណាមួយ (ពិការភាពទាំងស្រុង/មរណភាព)។
- រយៈពេលការការពារមានភាពបត់បែនដូចជា ៣, ៥, ៧, ១០, ១៥, ២០, ២៥, និង ៣០ ឆ្នាំ។

## 2. ហេតុអ្វីបានជាខ្ញុំត្រូវទិញគម្រោងនេះ?

- គម្រោងនេះអនុញ្ញាតឲ្យលោកអ្នកបង់បុព្វលាភរ៉ាប់រងទាប ហើយទទួលបានទំហំការការពារខ្ពស់។ គម្រោងនេះជួយលោកអ្នកឲ្យប្រាកដក្នុងចិត្តថាមនុស្សជាទីស្រឡាញ់ របស់លោកអ្នកនឹងអស់ក្តីបារម្ភលើបញ្ហាហិរញ្ញវត្ថុ ទោះជាបីជាគ្មានវត្តមានរបស់លោកអ្នកក៏ដោយ។

## 3. តើអ្នកណាអាចទិញគម្រោងនេះបាន?

- អ្នកដែលអាចទិញគម្រោងនេះបាន លុះត្រាតែមានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៦០ ឆ្នាំ។

## 4. តើមានជម្រើសអ្វីខ្លះក្នុងការបង់បុព្វលាភរ៉ាប់រង?

- ជម្រើសក្នុងការបង់បុព្វលាភរ៉ាប់រងមានពីរយ៉ាងដូចខាងក្រោម៖
  - ប្រចាំឆមាស (៦ ខែម្តង) និង
  - ប្រចាំឆ្នាំ។

## 5. តើខ្ញុំអាចទិញទំហំការការពាររហូតបានប៉ុន្មាន?

- ទំហំនៃការការពាររបស់គម្រោងនេះមានរហូតដល់ 500 000 (ហាសិបម៉ឺន) ដុល្លារអាមេរិក ដែលការបង់បុព្វលាភរ៉ាប់រងចាប់ផ្តើមពី 400 ដុល្លារអាមេរិក ក្នុងមួយឆ្នាំឡើងទៅ។

## 6. តើខ្ញុំអាចទិញ គម្រោងនេះ តាមរបៀបណា?

- លោកអ្នកអាចទិញគម្រោងនេះតាមរយៈ ទីប្រឹក្សាធានារ៉ាប់រង និងមន្ត្រីជំនាញប្រឹក្សាធានារ៉ាប់រងរបស់ក្រុមហ៊ុន មេនូឡាយហ្វ៍ ឬ លោកអ្នកអាចធ្វើដំណើរមកកាន់ការិយាល័យណាមួយរបស់ក្រុមហ៊ុនដែលនៅជិតលោកអ្នក ឬក៏ទាក់ទងមកកាន់ក្រុមហ៊ុនយើងខ្ញុំតាមរយៈ លេខទូរស័ព្ទ ១៨០០ ២១១ ២១១ ដោយឥតគិតថ្លៃ។

## 7. តើខ្ញុំនឹងទទួលបានប្រាក់ដែរឬទេនៅពេលដែលគម្រោងនេះដល់សុពលភាព?

- គម្រោងនេះគឺជាប្រភេទគម្រោងការពារសុទ្ធសាធ ដែលមានតម្លៃសមរម្យ បើធៀបទៅនឹងគម្រោងធានារ៉ាប់រងផ្សេងទៀត តែលោកអ្នកនឹងមិនទទួលបានទឹកប្រាក់នៅពេលដែលគម្រោងនេះដល់សុពលភាពឡើយ។ ការទទួលបានទឹកប្រាក់នៅពេលដែលគម្រោងដល់សុពលភាព មានចំពោះតែប្រភេទគម្រោងសន្សំតែប៉ុណ្ណោះ។

## 8. តើត្រូវចំណាយរយៈពេលប៉ុន្មានដើម្បីទូទាត់សំណង?

- ដើម្បីទូទាត់សំណង ក្រុមការងារត្រូវការរយៈពេល៥ថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលទទួលបានឯកសារចាំបាច់ទាំងអស់។

## 9. តើខ្ញុំអាចធ្វើការទាមទារសំណងយ៉ាងដូចម្តេច?

- លោកអ្នកអាចអនុវត្តតាមជំហានដូចខាងក្រោម៖

**ក.** សូមផ្តល់ដំណឹងជូនទីប្រឹក្សាធានារ៉ាប់រង ឬ ទាក់ទងមកកាន់ផ្នែកសេវាបម្រើអតិថិជនរបស់យើងខ្ញុំតាមរយៈ លេខទូរស័ព្ទ ១៨០០ ២១១ ២១១ ដោយឥតគិតថ្លៃ។

**ខ.** សូមអញ្ជើញមកកាន់ការិយាល័យរបស់ក្រុមហ៊ុនណាមួយដែលមានទីតាំងដែលនៅជិតលោកអ្នកបំផុត

**គ.** សូមទាក់ទងយើងខ្ញុំតាមរយៈអ៊ីមែល៖ customer_service_kh@maulife.com

**សំគាល់៖** យើងខ្ញុំនឹងជួយសម្រួលក្នុងការបំពេញទម្រង់បែបបទទាំងនោះ។